# ព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា សង្ខេប

LIBRARY
BUDDHIST INSTITUTE

សម្ដេចព្រះពោធិវង្ស ហួត តាត

រៀបរៀង

បោះពុម្ពលើកទី ២

ស. ២៥១៤ គ.ស. ១៩៧០

២១០.
៤

www.budinst.gov.kh www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org

# ព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា សង្ខេប

## សម្ដេចព្រះពោធិវង្ស ហួត តាត

រៀបរៀង

បោះពុម្ពលើកទី ២

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ព.ស. ១៥១៤ គ.ស. ១៩៧០

www.budinst.gov.kh www.elibraryofcambodia.org



សម្ដេចព្រះមហាសុមេធាធិបតី (ហ. តាត) វជិរប្បញ្ញោ

ព្រះសង្ឃនាយកគណៈមហានិកាយ

— អគ្គាធិការពុទ្ធិកសិក្សា កម្ពុជរដ្ឋ

— សកលវិទ្យាធិការនៃពុទ្ធិកសកលវិទ្យាល័យ

www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

អត្ថបទនិយាយពី ព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា សង្ខេបនេះ ខ្ញុំបានរៀបរៀងតាំងពីគ្រិស្តសករាជ ១៩៥១ ។ ក្រសួងធម្មការបានយកទៅបោះពុម្ពចែក ទុកជាអនុស្សាវរីយ៍ កាលក្នុងសម័យនៃមហាសន្និបាត ធ្វើសន្និសីទទី៦ នៃពុទ្ធិកសមាគមពិភពលោក នៅក្រុងភ្នំពេញ ពីថ្ងៃទី ១២ ដល់ថ្ងៃទី ២២ វិច្ឆិកា ១៩៦១ ម្តងរួចហើយ ។

ឥឡូវនេះ លោក **ឈាង ហ៊ប អាន** នាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ យល់ឃើញថា អត្ថបទនេះពិតជាសង្ខេបមែន ប៉ុន្តែមានប្រយោជន៍ច្រើនណាស់ ចំពោះអ្នកត្រូវការចង់ដឹង ហើយមិនងាយនឹងស្វែងរកបានឡើយ ទើបកើតមានសេចក្តីជ្រះថ្លា ហើយបានសូមអត្ថបទនេះយកទៅបោះពុម្ពម្តងទៀត ដើម្បីចែកក្នុងឱកាសសម្ពោធគ្រឹះស្ថាននៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត កាលពីថ្ងៃទី ១០ ខែកញ្ញា ១៩៦៧ ដោយលោកចេញបច្ច័យផ្ទាល់ខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំជាអ្នករៀបរៀង បានជូនអត្ថបទនេះចំពោះលោក **លាង ហ៊័បអាន** នាយកនៃវិជ្ជាបាន់ពុទ្ធសាសនបណ្ឌិត្យ ឲ្យបាត់ការបោះពុម្ពតាមសេចក្តីត្រូវការចុះ ដោយសេចក្តីរីករាយ និងសេចក្តីពេញចិត្តយ៉ាងក្រៃលែង ។

សម្តេចព្រះពោធិវង្ស

**ហួត តាត**

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីប្រារព្ធ

សៀវភៅឈ្មោះ "ព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា" នេះ គឺជាស្នាព្រះហស្តរបស់សម្តេច ព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក កាលព្រះអង្គគង់ក្នុងឋានន្តរសក្តិជាសម្តេចព្រះពោធិវង្សនៅឡើយ ។ សៀវភៅនេះបានបោះពុម្ពចែកជាធម្មទានម្តងរួចទៅហើយ កាលពីក្នុងឱកាសសម្ពោធគ្រឹះស្ថាននៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នាថ្ងៃទី១០ កញ្ញា ១៩៦៧ ។ ដោយសារថា សៀវភៅនេះ ជាឯកសារដ៏វិសេសសម្រាប់ការស្រាវជ្រាវ អំពីប្រវត្តិ និង គោលសំ-ខាន់ៗខ្លះក្នុងព្រះពុទ្ធសាសនានោះ ទើបវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យសម្រេចថានឹងបោះពុម្ពផ្សាយជាថ្មីទៀតវិញ ក្នុងពពួកសៀវភៅ "វប្បធម៌ និង អារ្យធម៌ខ្មែរ" ។

ភ្នំពេញ, ថ្ងៃទី ១ មករា ២៥១៣/១៩៦៩

**លាង ហ័ប អាន**

នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះពុទ្ធសាសនា នៅ ប្រទេសកម្ពុជា

## សង្ខេប

ព្រះពុទ្ធសាសនា ផ្សាយចូលមកប្រទេសកម្ពុជាមុន ដំបូងតាមគម្ពីរពុទ្ធសាសនា **សមន្តបាសាទិកាអដ្ឋកថា វិនយបិដក** ជាភាសាបាលី បានប្រាប់ពត៌មានថា កាលក្រោយពេលដែលធ្វើតតិយសង្គាយនារួចហើយ នៅក្នុងជម្ពូទ្វីបគឺប្រទេសឥណ្ឌា ក្នុងពុទ្ធសតវត្សរ៍ទី ៣ ព្រះមហាថេរ ១អង្គព្រះនាម **មហាមោគ្គលិបុត្តតិស្សៈ** បានចាត់ចែងបញ្ជូនព្រះថេរៈ ២ អង្គ គឺព្រះ **សោណត្ថេរ** និងព្រះ **ឧត្តរត្ថេរ** ឲ្យចេញពីជម្ពូទ្វីប "ឥណ្ឌា" មកផ្សាយព្រះពុទ្ធសាសនា នៅសុវណ្ណភូមិ ក្នុងគ្រាថេរមកផ្ទួ-បត្ថម្ភនៃព្រះមហាក្សត្រព្រះនាម **ធម្មាសោក** ។

www.budinst.gov.kh www.elibraryofcambodia.org

សុវណ្ណភូមិនោះ គឺប្រទេសខាងអាស៊ីអាគ្នេយ៍នេះឯង ដែលមានប្រទេស **កម្ពុជា** រួមនៅជាមួយផង ។ ប្រទេសទាំងឡាយនៅក្នុងអាស៊ីអាគ្នេយ៍ ទំនងសម្គាល់ថា សុវណ្ណភូមិនោះ ជាប្រទេសរបស់ខ្លួនមួយៗមិនសមទេ គួររួបរួមប្រទេសទាំងអស់ជាសុវណ្ណភូមិទើបសម ហើយពិតជាត្រូវផងទៀត ព្រោះប្រទេសកម្ពុជា យើងបានពិនិត្យតាមសិលាចារឹកបុរាណខ្លះ តាមប្រវត្តិសាស្ត្រផ្សេងៗខ្លះ ដែលទាក់ទងដល់រឿងព្រះពុទ្ធសាសនាឃើញថា ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា មានតាំងពីពុទ្ធសតវត្សរ៍ទី ៣ នោះមក ទើបសន្និដ្ឋានបានថា ព្រះពុទ្ធសាសនាដែលបានមកប្រតិស្ឋាននៅប្រទេសកម្ពុជា នៅក្នុងពុទ្ធសតវត្សរ៍ទី ៣ ដោយព្រះ **សោណត្ថេរ** និងព្រះ **ឧត្តរត្ថេរ** នាំមកផ្សាយតាមថេរបញ្ជា នៃព្រះ **មហាមោគ្គលិបុត្តតិស្សត្ថេរ** ក្នុងព្រះបរមរាជូបត្ថម្ភនៃព្រះបាទ **ធម្មាសោក** មហារាជ ។

តាំងពីពេលនោះដរាបមកដល់ពេលនេះ ព្រះពុទ្ធ-

www.budinst.gov.kh www.elibraryofcambodia.org

សាសនា ក្នុងប្រទេសកម្ពុជា អាចឋិតនៅបានជាដរាបតមក ឥតដែលមានវិនាសបាត់បង់ក្នុងពេលណាមួយឡើយ គ្រាន់តែមានការចុះថយ និងការចំរើនផ្លាស់ប្ដូរគ្នាប៉ុណ្ណោះ ដោយហេតុថាក្នុងពេលខ្លះ ព្រះពុទ្ធសាសនាបានទទួលការឧបត្ថម្ភយ៉ាងមាំមួនអំពីពុទ្ធសាសនិក ក្នុងពេលខ្លះ បានទទួលការឧបត្ថម្ភយ៉ាងស្ដួចស្ដើង ព្រោះក្នុងកាលដ៏យូរអង្វែងនេះ នៅក្នុងប្រទេសកម្ពុជាព្រះមហាក្សត្រិយ៍ក្ដី ឥស្សរជនក្ដី ប្រជា-ពលរដ្ឋក្ដី មិនបានឋិតនៅក្នុងសភាពដ៏ទៀងទាត់ឡើយ គឺជួនកាលជាពុទ្ធសាសនិកថេរវាទ ជួនកាលជាពុទ្ធសាសនិកមហាយាន ជួនកាលជាព្រាហ្មណិក ម្ល៉ោះហើយព្រះពុទ្ធ-សាសនា ក៏រមែងតែប្រែប្រួលទៅតាមកម្លាំងនៃជំនឿរបស់ពុទ្ធសាសនិកជន ដែលប្រែប្រួលទៅតាមកាលវេលា ប៉ុន្តែបើទុកជាយ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា គួរឲ្យអស្ចារ្យណាស់ ព្រោះបានឋិតនៅជាប់តមករហូតដល់បច្ចុប្បន្នកាលនេះ ដោយសារមានការឧបត្ថម្ភ

www.budinst.gov.kh www.elibraryofcambodia.org

ជាប់តមក ដោះបីការឧបត្ថម្ភនោះ ស្ដួចស្ដើងយ៉ាងណា ក៏មិនដែលមានដាច់សោះសូន្យឡើយ ។

## ការឧបត្ថម្ភព្រះពុទ្ធសាសនា

ដូចម្ដេចហៅថាការឧបត្ថម្ភព្រះពុទ្ធសាសនា ។ ការឧបត្ថម្ភនេះ គឺទំនុកបំរុងផ្គង់ផ្គើមគ្រប់បែបយ៉ាង ដើម្បីឲ្យព្រះពុទ្ធសាសនាបានចំរើនឡើងយ៉ាងទូលំទូលាយ ។ ចុះអ្នកណាជាអ្នកឧបត្ថម្ភព្រះពុទ្ធសាសនា ? អ្នកឧបត្ថម្ភព្រះពុទ្ធសាសនានោះ គឺអ្នកដែលមានសេចក្ដីជ្រះថ្លា មានជំនឿគោរពកប់អានចំពោះព្រះពុទ្ធសាសនា ដែលហៅថាពុទ្ធសាសនិកជន ឬហៅថាពុទ្ធបរិស័ទ បានដល់ព្រះមហាក្សត្រិយ៍ ឥស្សរជន និងប្រជាពលរដ្ឋទូទៅក្នុងប្រទេស ។

ក្នុងប្រទេសកម្ពុជាយើងនេះ តាមសិលាចារិកបុរាណ និងតាមឯកសារផ្សេងៗ ដែលទាក់ទងនឹងព្រះពុទ្ធសាសនា ឃើញថាព្រះមហាក្សត្រិយពីបុរាណកាល ដូចជាព្រះបាទ **កៅណ្ឌិន្យជយវរ្ម័ន** ជាដើម រហូតដល់មកព្រះបាទ

www.budinst.gov.kh www.elibraryofcambodia.org

**ជយវរ្ម័នទី១** ព្រះអង្គជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងមាំមួនណាស់ បានទំនុកបំរុងព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿងឡើងដោយលំដាប់ ទាំងខាងសម្ភារៈ ទាំងខាងការសិក្សា ។ មិនតែប៉ុណ្ណោះ ទ្រង់បំបួសព្រះរាជបុត្រ ២ អង្គជាភិក្ខុក្នុងព្រះពុទ្ធសាសនាផងទៀត ដើម្បីឲ្យបានជាព្រះញាតិទឹងព្រះពុទ្ធសាសនា ភិក្ខុ ១ រូប ឈ្មោះ **រតនភាណុ** ១ រូបទៀតឈ្មោះ **រតនសិទ្ធៈ** ។

លំដាប់តមកទៀត ដល់មករជ្ជកាលព្រះមហាក្សត្រិយ៍ព្រះនាម **ជយវរ្ម័នទី ៧** ព្រះអង្គគង់នៅរាជធានីមហា-នគរ «**នគរធំ**» ក្នុងគ្រិស្តសករាជ ១១៨១ ទ្រង់ជាពុទ្ធសាសនិក ១ អង្គដ៏ប្រសើរ ។ ព្រះអង្គមានសទ្ធាជ្រះថ្លាយ៉ាងខ្លាំង បានកសាងវត្តអារាម ទំនុកបំរុងព្រះភិក្ខុសង្ឃ បានបំពេញព្រះរាជកុសលធ្វើពុទ្ធបូជា ដោយវត្ថុមានតម្លៃយ៉ាងច្រើនជាអនេក ។ មិនតែប៉ុណ្ណោះ ទ្រង់បានបញ្ជូនព្រះរាជ-ឱរសមួយអង្គ ឲ្យទៅសិក្សាវិជ្ជាខាងព្រះពុទ្ធសាសនា ឯ

www.budinst.gov.kh www.elibraryofcambodia.org

លង្កាទ្វីប ព្រះរាជបុត្រនោះ ក៏បានបួសជាភិក្ខុក្នុងវត្តមហា-វិហារមាននាមថា **តាមលិន្ទះ** ក្នុងគ្រឹស្តសករាជ ១១៩០ ។

សេចក្ដីសង្ខេបខាងលើនេះ គ្រាន់តែបញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា បានជាប់តមកមិនដាច់ ដោយមានការឧបត្ថម្ភអំពីព្រះមហាក្សត្រិយ៍ជាដើម រហូតដល់ប្រជារាស្ត្រ ដែលមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយបានយកចិត្តទុកដាក់គោរពរាប់អានតៗគ្នាមក រហូតដល់បច្ចុប្បន្នកាល ។

## ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា
## នាបច្ចុប្បន្ន

ក្នុងបច្ចុប្បន្នកាលនេះ ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា មានការលូតលាស់ផុះផុលចំរើនយ៉ាងខ្លាំង ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ប្រទេសកម្ពុជាបានស្ថិតនៅក្នុងឋានៈ ជាប្រទេសឯករាជ្យ កាន់នយោបាយអព្យាក្រឹត្យ មានសិទ្ធិនិងសេរីភាពបរិបូណ៌ ។ ប្រទេសកម្ពុជា

www.budinst.gov.kh www.elibraryofcambodia.org

កប្រទេសមានកិត្តិ ដោយមានសម្តេច **ព្រះនរោត្តម សីហនុ ព្រះឧបយុវរាជ ជាព្រះប្រមុខរដ្ឋ** ជាព្រះអគ្គមគ្គុទ្ទេសក៍ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ព្រះអង្គជានាយកដឹកនាំប្រទេសឲ្យប្រជារាស្ត្ររួចផុតពីទុក្ខភ័យពីគ្រោះថ្នាក់ ឲ្យបានឋិតនៅក្នុងសុខសន្តិភាព ឲ្យបានជួបនឹងការសម្បូណ៌សប្បាយ ។ រីឯព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជានាបច្ចុប្បន្នកាលនេះ ក៏ប្រព្រឹត្តទៅកាន់សេចក្តីចំរើនដោយលំដាប់ តាមដំណើរនៃប្រទេស ព្រោះព្រះពុទ្ធសាសនាជាប់ទាក់ទងជាមួយគ្នានឹងប្រទេសដែរ, បើប្រទេសមានទុក្ខព្រះពុទ្ធសាសនាក៏មានទុក្ខ បើប្រទេសបានសុខចំរើន ព្រះពុទ្ធសាសនាក៏បានសុខចំរើនដែរ ។

សម្តេច **ព្រះនរោត្តមសីហនុ** កាលព្រះអង្គគង់នៅលើរាជបល្ល័ង្ក ជាព្រះមហាក្សត្រិយ៍នៅឡើយ ព្រះអង្គបានប្រោសព្រះរាជទាន រដ្ឋធម្មនុញ្ញដល់ប្រជារាស្ត្ររបស់ព្រះអង្គ ក្នុងរដ្ឋធម្មនុញ្ញនោះ ត្រង់ប្រការ ៨ បានលើកយក

www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធសាសនាឲ្យជាសាសនារបស់រដ្ឋ ។ ត្រង់នេះហើយ ដែលជាកស្តុតាង នៃព្រះរាជហឫទ័យរបស់ព្រះអង្គ ជាអគ្គ-ពុទ្ធសាសនូបត្ថម្ភក៍ ទ្រង់គោរពកប់អាន ទំនុកបំរុងព្រះពុទ្ធ-សាសនាដោយស្មោះបំពោះ គឺទ្រង់ចំណាយព្រះរាជទ្រព្យ កសាងវត្តអារាម ព្រះចេតិយ៍ និងព្រះរាជកុសលផ្សេងៗ មានកសាងពុទ្ធិកមហាវិទ្យាល័យជាដើម មិនតែប៉ុណ្ណោះ ព្រះអង្គបានតាំងទ្រង់ព្រះផ្នួសជាភិក្ខុក្នុងព្រះពុទ្ធសាសនាអស់រយៈកាលពាវខែផងទៀត ដើម្បីបំពេញព្រះរាជករណីយ-កិច្ច តាមព្រះរាជប្រវេណី ដែលព្រះរាជវង្សានុវង្ស ធ្លាប់បំ-ពេញមកផង ដើម្បីទ្រង់បានសិក្សាច្បាប់ព្រះពុទ្ធសាសនា ឲ្យបានជ្រាបយ៉ាងច្បាស់លាស់ផង ឲ្យបានសមដល់ព្រះរាជឋានៈរបស់ព្រះអង្គ ជាព្រះអគ្គពុទ្ធសាសនិក ។

ព្រះមហាក្សត្រិយ៍មុនៗ ដែលត្រូវជាព្រះរាជអយ្យកោ ព្រះរាជអយ្យិកា ព្រះវររាជបិតា ព្រះវររាជមាតា របស់ព្រះអង្គ ក៏សុទ្ធតែជាព្រះអគ្គពុទ្ធសាសនិកទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រជាពលរដ្ឋនៃប្រទេសកម្ពុជាមានចំនួនជាង ៦ លាននាក់ ។ ក្នុងចំនួននេះ មានប្រជាពលរដ្ឋ ៩៩ ភាគរយជាអ្នកកាន់ព្រះពុទ្ធសាសនា ។

ដោយអាស្រ័យហេតុដូចខាងលើនេះ ទើបរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ដែលជាអង្គការណ៍គ្រប់គ្រងរដ្ឋ បានចាត់ការរៀបចំឲ្យមានក្រសួងមួយហៅថា ក្រសួងធម្មការ ហើយឲ្យមានសមាជិកនៃរាជរដ្ឋាភិបាលមួយនាក់ មានឋានៈជារដ្ឋមន្ត្រី ឬ ជារដ្ឋលេខាធិការ កាន់កាប់ក្រសួងនេះ ។ ក្រសួងធម្មការនេះ កាន់កាះខាងផ្នែកសាសនាទាំងអស់ ដែលមាននៅក្នុងប្រទេសកម្ពុជា ជាពិសេសបំផុតគឺកាន់កាប់កិច្ចការខាងព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ។

ក្រសួងធម្មការ បានចាត់ការរៀបចំកិច្ចការខាងព្រះពុទ្ធសាសនាតាំងពីក្នុងអតីតកាល ដរាបដល់បច្ចុប្បន្នកាលនេះ ឲ្យមានអង្គការណ៍សម្រាប់ធ្វើឲ្យព្រះពុទ្ធសាសនាមាន

www.budinst.gov.kh www.elibraryofcambodia.org

ការរៀបរយ នឹងការប្រព្រឹត្តទៅ កាន់សេចក្តីចំរើនរុងរឿង តាំងអង្គការណ៍របស់ឯកជនឯទៀត ៗ ដែលសម្រាប់ជួយឧបត្ថម្ភព្រះពុទ្ធសាសនា ក៏ឋិតនៅក្នុងអំណាច នៃក្រសួងធម្មការដែរ ។

អង្គការណ៍នោះមានដូចតទៅនេះ :

## ១-អង្គការគ្រប់គ្រងគណះសង្ឃ

## ខាងព្រះពុទ្ធសាសនា

អង្គការនេះ ក្រសួងធម្មការបានចាត់ការឲ្យមានព្រះរាជក្រមសម្រេចអំពីការរៀបចំដូចខាងក្រោមនេះគឺ :

**ក**- មានសម្តេច **ព្រះសង្ឃរាជ** ឬ **សម្តេចព្រះសង្ឃនាយក** ជាអ្នកត្រួតត្រាលើព្រះសង្ឃ ក្នុងព្រះរាជាណាចក្រទាំងមូល ជាពិសេសលើលោកមេគណគ្រប់ខេត្ត ដោយមានព្រះរាជាគណៈ ថ្នាក់ឯក-ទោ-ត្រីចត្វា ជួយធ្វើការផង

www.budinst.gov.kh www.elibraryofcambodia.org

ខ- មានលោកមេគណ ១ រូប ជាអ្នកត្រួតត្រាលើព្រះសង្ឃទាំងអស់ ក្នុងខេត្តនីមួយ ៗ ជាពិសេសលើលោកអនុគណគ្រប់ស្រុកដែលមានក្នុងខេត្តនីមួយ ៗ

គ- មានលោកអនុគណ ១ រូប ជាអ្នកត្រួតត្រាលើព្រះសង្ឃទាំងអស់ ក្នុងស្រុកនីមួយ ៗ ជាពិសេសលើលោកចៅអធិការគ្រប់វត្ត ដែលមាននៅក្នុងស្រុកនីមួយ ៗ

ឃ- មានលោកចៅអធិការ ១ រូប ដោយមានលោកគ្រូសូត្រស្តាំ ឆ្វេង អមផង ជាអ្នកត្រួតលើព្រះសង្ឃទាំងអស់ក្នុងវត្តនីមួយៗ

ង- មានគ្រហស្ថ១នាក់ជាអាចារ្យសម្រាប់វត្តនីមួយៗជាតំណាងព្រះសង្ឃក្នុងវត្តនីមួយ ៗ ក្នុងពេលដែលមានកិច្ចការទាក់ទងនិងរាជរដ្ឋាភិបាល ព្រមទាំងមានគណៈកម្មការ ១ ក្រុម សម្រាប់ជួយព្រះសង្ឃក្នុងវត្តនីមួយៗផង ទៀត ។

## ២- អង្គការថេរសភាមួយក្រុម

អង្គការនេះ នៅអមសម្តេចព្រះសង្ឃរាជ ឬ សម្តេចព្រះសង្ឃនាយក

www.budinst.gov.kh www.elibraryofcambodia.org

សម្រាប់វិនិច្ឆ័យអធិករណ៍ ក្នុងព្រះពុទ្ធសាសនា ដែលកើតឡើងរវាងសង្ឃនិងសង្ឃឬសង្ឃនិងគ្រហស្ថ ។

៣– សង្ឃមហាសន្និបាតប្រចាំឆ្នាំ ក្នុងមួយឆ្នាំៗមានការប្រជុំសង្ឃជាមហាសន្និបាតម្តង គឺលោកមេគណគ្រប់ខេត្ត អនុគណគ្រប់ស្រុក និងភិក្ខុជាសហការីទាំងអស់ដែលនៅតាមខេត្ត ស្រុក មកប្រជុំនៅទីក្រុងភ្នំពេញ រួបរួមជាមួយនឹងព្រះរាជាគណៈ ហានានុក្រមទាំងអស់ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃរាជឬសម្តេចព្រះសង្ឃនាយក ។

៤– អង្គការសិក្សាខាងព្រះពុទ្ធសាសនា ការសិក្សានេះហៅពុទ្ធិកសិក្សាៗ នេះមាន ៣ ប្រភេទគឺ : (១)

---

១) ក្នុងឆ្នាំ១៩៦៩នេះសាលាពុទ្ធិកបឋមសិក្សាមាន ២៩១ ថ្នាក់ មានសមណសិស្ស ៩៥៤៥ រូប ។ សាលាពុទ្ធិកមធ្យមសិក្សាមាន ២៤ ថ្នាក់មានសមណសិស្ស១០៥០រូប ។ ពុទ្ធិកឧត្តមសិក្សាមានសមណនិស្សិតចំនួន ១៧៦ រូប គឺនៅឧត្តមសិក្សាបឋមភូមិមាន ១២៩ រូបនិងឧត្តមសិក្សាទុតិយភូមិមាន ៤៧ រូប ។

www.budinst.gov.kh www.elibraryofcambodia.org

ក– ពុទ្ធិកបឋមសិក្សា ការសិក្សាដំបូង នៃភិក្ខុសាមណេរ កំណត់ការសិក្សា ៣ ឆ្នាំ

ខ– ពុទ្ធិកមធ្យមសិក្សា ការសិក្សាជាន់មធ្យមនៃភិក្ខុសាមណេរ កំណត់កាលសិក្សា ៤ ឆ្នាំ

គ– ឧត្តមសិក្សា ការសិក្សាជាន់ខ្ពស់ នៃភិក្ខុសាមណេរ កំណត់កាលសិក្សា ១០ ឆ្នាំ ។ ការសិក្សានេះចែកជា ៣ ភូមិគឺ បឋមភូមិត្រូវសិក្សា ៣ ឆ្នាំ ទុតិយភូមិត្រូវសិក្សា ៤ ឆ្នាំ តតិយភូមិ ឬ ភូមិទីបំផុតត្រូវសិក្សា ៣ ឆ្នាំ រួមពេលសិក្សាទាំង ៣ ភូមិត្រូវជា ១០ ឆ្នាំ ។

---

ក្រៅការសិក្សាទាំង ៣ ខាងលើនេះ មានការសិក្សាមួយផ្សេងទៀត ហៅថាការសិក្សាធម៌វិន័យឬសាលាធម៌វិន័យ ។ នេះសម្រាប់ភិក្ខុសាមណេរ ជាសាធារណៈ គឺអ្នកបួសទាំងឡាយគ្រប់វត្តអារាមក្នុងប្រទេសកម្ពុជា ត្រូវតែសិក្សាគ្រប់គ្នាខានពុំបាន ។

៥– ពុទ្ធសាសនបណ្ឌិត្យ ជាអង្គការមួយនៅក្រោម

www.budinst.gov.kh www.elibraryofcambodia.org

អំណាចនៃក្រសួងធម្មការ ។ អង្គការនេះសម្រាប់ចាត់ការធ្វើឲ្យបានចំរើនដល់ប្រទេសនិងព្រះពុទ្ធសាសនា គឺបានបង្កើតជាអង្គការសាខា ៣ ទៅទៀត ដូចមានតទៅនេះគឺ:

ក– បណ្ណាល័យសម្រាប់តម្កល់គម្ពីរ ដីកា ស៊ឹករឹត និងសៀវភៅផ្សេងៗ ព្រមទាំងចាត់ការបោះពុម្ពសៀវភៅភាសាបាលីខ្លះ ភាសាជាតិខ្លះ ។

ខ– ក្រុមជំនុំព្រះត្រៃបិដក សម្រាប់ប្រែ ព្រះត្រៃបិដកបាលីជាភាសាជាតិ ហើយបោះពុម្ពជាសៀវភៅ ។

~~គ– ក្រុមជំនុំទំនៀមទម្លាប់ សម្រាប់ស្វែងរកព្រម~~ ទាំងគ្រប់គ្រងរក្សានូវច្បាប់ទំនៀមទម្លាប់របស់ជាតិខ្មែរ ឲ្យបានគង់វង្សតទៅ ។

៦– ពុទ្ធិកសមាគមកម្ពុជរដ្ឋ (ជាអង្គការឯកជន) សម្រាប់ជួយឧបត្ថម្ភព្រះពុទ្ធសាសនាក្នុងប្រទេស ផង ក្រៅប្រទេសផង មានការសិក្សាជាដើម

៧– សមាគមមិត្រពុទ្ធិកវិទ្យាល័យ (ជា អង្គការ

www.budinst.gov.kh www.elibraryofcambodia.org

ឯកជន ) សម្រាប់ជួយឧបត្ថម្ភ ចំពោះកិច្ចការខាងព្រះពុទ្ធសាសនាក្នុងប្រទេសដោយច្រើន គឺជួយឧបត្ថម្ភពួកសមណនិស្សិត ។

៨- សមាគមគិលានដ្ឋាន មហាក្សត្រិយានី (ជាអង្គការឯកជន ) សម្រាប់ជួយព្យាបាលរោគព្រះសង្ឃខាងព្រះពុទ្ធសាសនា ។

ក្រៅអំពីអង្គការខាងលើនេះ កិច្ចការទាំងឡាយណាដែលទាក់ទងនឹងព្រះពុទ្ធសាសនា កិច្ចការទាំងនោះត្រូវជាភារៈលើក្រសួងធម្មការទាំងអស់ ។

## វត្តអារាម និង ភិក្ខុសាមណេរ

វត្តអារាមខាងព្រះពុទ្ធសាសនា នៅក្នុងប្រទេសកម្ពុជានេះ មិនមែនទើបនឹងកើតមានក្នុងពេលថ្មីៗនេះទេ គឺកើតមានជាយូរអង្វែងមកហើយ ដំណាលគ្នានឹងការប្រតិស្ឋាននៃព្រះពុទ្ធសាសនាហើយកើតមានព្រះសង្ឃ គឺភិក្ខុសាម-ណេរ ក្នុងពេលណា វត្តអារាមក៏ត្រូវកើតមានក្នុងពេល

www.budinst.gov.kh www.elibraryofcambodia.org

នោះ ព្រោះវត្តអារាមជាទីលំនៅនៃព្រះសង្ឃ ប៉ុន្តែវត្តអារាម នោះល្អឬមិនល្អ តូចឬធំ នោះមិនទៀងទាត់ទេ គឺសាង តម្រូវតាមកាលៈទេសៈ ។

ក្នុងបច្ចុប្បន្នកាលនេះ វត្តអារាមទាំងឡាយក្នុងប្រទេស កម្ពុជា ច្រើនតែបានផ្លាស់ប្តូររូបរាងជាថ្មី ដោយអាស្រ័យ កម្លាំងសទ្ធាជ្រះថ្លានៃពុទ្ធបរិស័ទ ។ វត្តណាដែលមានវិហារ សាលា កុដិចាស់ ៗ វត្តនោះ ត្រូវបានកសាងឡើងជាថ្មី ដោយគ្រឿងបេតុងអារ៉ម៉េ ព្រោះក្នុងសម័យនេះ សម្បូណ៌ ដោយគ្រឿងដែកស៊ីម៉ង់ត៍និងឥដ្ឋ ។

សព្វថ្ងៃនេះ វត្តអារាមខាងព្រះពុទ្ធសាសនាក្នុង ប្រទេសកម្ពុជាទាំងមូល មានចំនួន ២.៨៥០ វត្ត បំណែក ព្រះសង្ឃគឺ ភិក្ខុ-សាមណេរ ដែលអាស្រ័យនៅក្នុងវត្ត អារាម មានចំនួនតែ ៥៣.៥០៩ រូប នេះគិតក្នុងឆ្នាំ ១៩៦១ នេះ បើយកចំនួនព្រះសង្ឃ ៥៣.៥០៩ រូប ទៅចែកតាម

www.budinst.gov.kh www.elibraryofcambodia.org

ចំនួនវត្ត ២៨៥០ ឃើញក្នុងមួយវត្តៗមានភិក្ខុ សាមណេរ តែត្រឹម ១៨ រូប (១) ។

## វត្តអារាម និង ប្រជាពលរដ្ឋខ្មែរ

ព្រះពុទ្ធសាសនា ដែលមកប្រតិស្ឋានក្នុងប្រទេសកម្ពុជា យូរជាង ២០០០ ឆ្នាំ ហើយបានជ្រួតជ្រាបដិតជាប់ក្នុងចិត្តគំនិតនៃប្រជាពលរដ្ឋខ្មែរ ក្នុងព្រះរាជាណាចក្រទាំងមូល ។

ប្រជាកស្ត្រខ្មែរ បើបានទៅតាំងទីភូមិករ នៅកន្លែងណាមួយ បើមានគ្នាចំនួន ៥០-៦០ គ្រួសារឡើងទៅ រមែងពេញចិត្តនឹងកសាងវត្តអារាមខាងព្រះពុទ្ធសាសនា ឲ្យមាននៅជិតភូមិលំនៅ ហើយនិមន្តភិក្ខុ សាមណេរ ទៅគង់ក្នុងវត្តថ្មីនោះ ដើម្បីផ្ញើអាយុជីវិតរបស់ខ្លួនទៅលើវត្តអារាម

(១) បើគិតក្នុងឆ្នាំ ១៩៦៩ នេះចំនួនវត្ត មាន ៣៣៦៩ គឺវត្តគណៈមហានិកាយ មាន ៣២៣០ និងគណៈធម្មយុត្តិកនិកាយ មាន ១៣៩ ។ ឯចំនួនព្រះសង្ឃមាន ៦៥.០៦២ ខាងមហានិកាយ ៦២.៦៧៨ និងធម្មយុត្តិ ២៣៨៤ អង្គ ។

បណ្ណាល័យ LIBRARY

www.budinst.gov.kh www.elibraryofcambodia.org

នោះតែម្តងទុកទីវត្តនោះ ជាបង្អែកយ៉ាងមាំខាងផ្លូវចិត្ត បាន ជាប្រទេសកម្ពុជាយើងនេះ មានវត្តអារាមច្រើន ដល់ទៅ ២.៨៥០ វត្ត ។ វត្តមានចំនួនប៉ុណ្ណេះ សម្រាប់ពលរដ្ឋខ្មែរដែលមានចំនួនជាង ៦ លាននាក់ ហើយគិតយកចំនួន ៩៩ភាគរយ នៃប្រជាពលរដ្ឋខ្មែរ ទុកជាអ្នកកាន់ព្រះពុទ្ធសាសនា បើយកទៅប្រៀបធៀបនឹងប្រទេស ដែលកាន់ព្រះពុទ្ធសាសនាដូចប្រទេសយើង គឺប្រទេសថៃ និងប្រទេសភូមានោះ ឃើញថាវត្តអារាមព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា ដែលមានដូចចំនួនខាងលើនេះ មិនត្រូវទុកថាមានច្រើនពេកទេ គឺគ្រាន់តែល្មមប៉ុណ្ណោះឯង ។ ប្រជាពលរដ្ឋខ្មែរ ដែលកាន់ព្រះពុទ្ធសាសនា តាំងពីក្នុងអតីតសម័យដរាបដល់បច្ចុប្បន្នសម័យនេះ បានជាពេញចិត្តកសាងវត្តអារាមសម្រាប់ព្រះសង្ឃគង់នៅ ឲ្យមាននៅក្នុងទីប្រជុំភូមិភាគនីមួយៗនោះ ដោយឃើញថាវត្តអារាមនោះ មានប្រយោជន៍ច្រើនណាស់គឺ ៖

www.budinst.gov.kh www.elibraryofcambodia.org

១— វត្តអារាមជាទីតាំងនៃព្រះពុទ្ធសាសនា ដែលខ្មែរទុកជាទីពឹងពំនាក់ ។

២— វត្តអារាមជាកន្លែងសិក្សាវិជ្ជាផ្សេងៗ មានអក្សរសាស្ត្រ-គណិតសាស្ត្រ និង សិល្បសាស្ត្រជាដើម ឲ្យល្មមដល់ជីវភាពរបស់ខ្លួនជាប្រជាពលរដ្ឋ ព្រមទាំងវិជ្ជាខាងព្រះពុទ្ធសាសនា ដែលគេគួរឲ្យចេះដឹង ឲ្យសមដល់ឋានៈរបស់ខ្លួន ជាអ្នកកាន់ព្រះពុទ្ធសាសនា ព្រោះក្នុងសម័យបុរាណ មិនមានសាលាសិក្សាក្រៅពីវត្តអារាមឡើយ ។

៣— វត្តអារាមជាមន្ទីរពេទ្យខាងផ្លូវចិត្ត សម្រាប់ប្រជាពលរដ្ឋនៅជុំវិញ គឺថា បើកាលណាមានសេចក្តីទុក្ខព្រួយដែលកើតពីហេតុណាមួយ ត្រូវចូលទៅវត្តអារាម រៀបរាប់ឲ្យព្រះសង្ឃបានជ្រាប ដើម្បីឲ្យលោកជួយពន្យល់ធម៌តាមផ្លូវព្រះពុទ្ធសាសនា ឲ្យបានរំលត់ទុក្ខព្រួយ ។

៤— វត្តអារាមទុកជាសួនច្បារមួយ សម្រាប់ប្រជាពលរដ្ឋដែលនៅជុំវិញ ។ បើកាលណាអផ្សុកមិនសប្បាយ

www.budinst.gov.kh www.elibraryofcambodia.org

ចិត្ត ដោយហេតុណាមួយ ត្រូវចូលទៅកាន់ទីវត្តអារាម ដែលមានទីកន្លែងទូលំទូលាយជាទីរមណីយដ្ឋាន លុះបានដើរលំហែមួយស្របក់ ក៏ត្រឡប់បានធូរស្រួលសប្បាយឡើងវិញ ។

៥- វត្តអារាមជាទីបញ្ចុះ សម្រាប់បូជាសពនៃប្រជាពលរដ្ឋ ។ ក្នុងពេលដែលមាតាបិតា ញាតិសន្តាន ព្រៀងលានទាំងប៉ុន្មានធ្វើមរណកាល ប្រជាពលរដ្ឋតែងនាំសពទៅធ្វើឈាបនកិច្ចក្នុងទីវត្ត ។ ក្រោយធ្វើឈាបនកិច្ច រើសអដ្ឋិតម្កល់ក្នុងកោដ្ឋហើយធ្វើបុណ្យក្នុងវត្តទៀត ដល់ទីបំផុត ធ្វើចេតិយក្នុងវត្ត ហើយបញ្ចុះអដ្ឋិធាតុមាតាបិតាជាដើម ក្នុងចេតិយនោះតែម្តង ។ ត្រង់នេះនាំឱ្យឃើញថា ប្រជាពលរដ្ឋ ទីពឹងលើវត្តអារាម តាំងពីនៅរស់ដរាបដល់ស្លាប់ ហើយទៅតែផ្ញើខ្លួនលើទីវត្ត គឺទីពឹងតាំងពីរស់ដល់ស្លាប់ ។

៦- វត្តអារាមជាកន្លែងសម្រាប់ផ្តល់នូវបុណ្យកុសល គ្រប់យ៉ាង ដល់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋដែលកាន់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធសាសនា ពេលណាត្រូវការធ្វើបុណ្យទានរក្សាសីល និងភាវនា ក៏រមែងតែចូលទៅរកវត្តអារាមជាដរាប ព្រោះមានភិក្ខុសង្ឃនៅទីនោះ លោកអាចជួយពន្យល់ពីបុណ្យទាន ពីការរក្សាសីលនិងពីការភាវនាជាដើម ដើម្បីឲ្យប្រជាពលរដ្ឋបានដឹងហើយកើតសេចក្ដីជ្រះថ្លាឡើង ៗ ដូច្នេះទីវត្តអារាមទុកដូចជាថ្នាលសម្រាប់បណ្ដុះពូជជាតនៃបុណ្យកុសលគ្រប់យ៉ាង ដែលជាគុណសម្បទឲ្យសម្រេចនូវសេចក្ដីសុខប្រាសចាកទុក្ខ ។

៧— វត្តអារាមជាទីជ្រោកកោននៃកូនចៅរបស់ប្រជាពលរដ្ឋ ៗ ក្នុងបច្ចុប្បន្នកាលនេះរាជរដ្ឋាភិបាលបានបាត់ការកសាងសាលាសិក្សាថ្នាក់បឋម ថ្នាក់មធ្យម និងថ្នាក់ឧត្ដមនៅខាងក្រៅវត្តអារាមពិតមែនហើយ ប៉ុន្តែកូនចៅអ្នកស្រុកដែលមកពីទីឆ្ងាយ ៗ ចូលទៅសិក្សាក្នុងសាលាទាំងនោះទោះនៅក្នុងរាជធានីក្ដី ក្នុងខេត្តក្ដី ក្នុងស្រុកក្ដី ឥតមានទីសំណាក់អាស្រ័យឡើយ និង រកជួលកន្លែងសំណាក់ពុំ

www.budinst.gov.kh www.elibraryofcambodia.org

កើត មកពីមាតាបិតាក្រីក្រ មិនអាចនឹងចេញថ្លៃទីសំណាក់ផង ថ្លៃអាហារផង ម្ល៉ោះហើយនិស្សិតទាំងនោះ ត្រូវចូលទៅសូមសំណាក់ អាស្រ័យនៅក្នុងវត្តអារាម ព្រមទាំងចិញ្ចឹមជីវិតខ្លួន ដោយសារព្រះសង្ឃក្នុងវត្តអារាមនោះទៀតផង ស្ទើរតែគ្រប់កន្លែង ។

ដោយវត្តអារាមខាងព្រះពុទ្ធសាសនា អាចផ្តល់ប្រ-

---

យោជន៍យ៉ាងច្រើន ជាប្រយោជន៍ដែលគេមិនបានគិត ឥតដឹងសោះ ដូចរៀបរាប់ខាងលើនេះហើយ ដែលនាំឲ្យប្រជាពលរដ្ឋខ្មែរតាំងពីបុរាណកាល រហូតដល់បច្ចុប្បន្នកាល មិនអាចនឹងតាំងភូមិករផ្ទះសម្បែងអាស្រ័យនៅ ដោយឥតមានទីវត្តអារាម ព្រះពុទ្ធសាសនា នៅជិតខាងបានឡើយ ។

ដូច្នេះ សរុបសេចក្តីទៅ ឃើញថាវត្តអារាមព្រះពុទ្ធ-សាសនា នៅប្រទេសកម្ពុជា ដែលមាន ២.៨៥០ វត្ត ពិតជាមានប្រយោជន៍យ៉ាងធំទូលំទូលាយ ដល់ព្រះពុទ្ធសាសនា ដល់ពលរដ្ឋ ដល់ប្រទេសជាតិ ដោយហេតុថា ដូចជាបាន

www.budinst.gov.kh www.elibraryofcambodia.org

ជួយសម្រាលបន្ទុករបស់រាជរដ្ឋាភិបាលមួយចំណែកដែរ ។

## ប្រជាពលរដ្ឋខ្មែរ មានជំនឿចំពោះ ព្រះពុទ្ធសាសនា

ប្រជាពលរដ្ឋខ្មែរ ក្នុងប្រទេសកម្ពុជា មានចំនួន ៩៩ ភាគរយ ដែលមានជំនឿជឿជាក់ចំពោះព្រះពុទ្ធសាសនា ហើយនាំគ្នាគោរពប្រតិបត្តិកាន់តាមឱវាទ ឬពាក្យប្រដៅនៃព្រះពុទ្ធជាម្ចាស់ តាំងពីច្រើនសតវត្សរ៍មកហើយ ។

ប្រជាពលរដ្ឋខ្មែរ ដែលមានជំនឿចំពោះព្រះពុទ្ធសាសនា គឺមានជំនឿយ៉ាងដូចម្តេចទៅ ។

ប្រជាពលរដ្ឋខ្មែរ ដែលមានជំនឿចំពោះព្រះពុទ្ធសាសនានេះ បើពោលដោយសង្ខេប គឺមានជំនឿថា ព្រះពុទ្ធសាសនាជាសាសនាប្រកបដោយហេតុផល ជាសាសនាប្រកាសនូវសេចក្តីពិត ជាសាសនាប្រាប់ឲ្យលះបង់សេចក្តីអាក្រក់ ឲ្យធ្វើសេចក្តីល្អ ជាសាសនាដឹកនាំសត្តនិករឲ្យងាកចេញពីផ្លូវខុស ឲ្យដើរទៅរកតាមផ្លូវត្រូវ ជា

www.budinst.gov.kh www.elibraryofcambodia.org

សាសនាជួយសត្វលោក ឲ្យស្គាល់មធ្យោបាយដោះខ្លួន ឲ្យរួចផុតពីទុក្ខ ឲ្យបានសម្រេចដល់នូវសេចក្តីសុខក្សេមក្សាន្ត។

នេះជាជំនឿយ៉ាងសង្ខេបនៃប្រជាពលរដ្ឋខ្មែរ ។

ដោយអាស្រ័យជំនឿយ៉ាងមាំមួន ចំពោះព្រះពុទ្ធសាសនា ដូចខាងលើនេះហើយ ទើបប្រជារាស្ត្រខ្មែរខំប្រឹងប្រតិបត្តិធ្វើតាមព្រះពុទ្ធឱវាទ គឺខំលះបង់អំពើអាក្រក់ (បាប) ហើយខំប្រឹងធ្វើអំពើល្អ (បុណ្យ) ច្រើនបែបច្រើនយ៉ាងដូចតទៅនេះ ៖

**១ – ធ្វើទាន** គឺលះសេចក្តីកំណាញ់បរិច្ចាគទ្រព្យរបស់ខ្លួន ចែកចាយដល់អ្នកដទៃ ដោយសេចក្តីសង្គ្រោះ ឲ្យគេបានសុខស្រួលផង ឬ បរិច្ចាគទ្រព្យបំពេញការកុសលផ្សេង ៗ គឺ

**ក – ប្រគេនចីវរបច្ច័យ** គឺស្បង់ចីពរដល់ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ឬចែកសំពត់អាវគ្រឿងស្លៀកពាក់ដល់ជនដែលទាល់ក្រទូទៅ មិនចំពោះមនុស្សណាមួយ

www.budinst.gov.kh www.elibraryofcambodia.org

ខ- ប្រគេនបិណ្ឌបាតប្បច្ច័យ គឺភោជនាហារដល់ព្រះសង្ឃ ក្នុងព្រះពុទ្ធសាសនា ឬឲ្យភោជនាហារដល់សាធារណជនដែលក្រីក្រ

គ- ប្រគេនសេនាសនប្បច្ច័យ គឺគ្រឿងដេកអង្គុយ មានកន្ទេលខ្នើយជាដើម ឬកសាងវត្ថុអាការក្នុងព្រះពុទ្ធសាសនា មានវិហារ សាលា កុដិ ជាដើម ឧទ្ទិសចំពោះព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ឬ ក៏ឲ្យគ្រឿងដេក អង្គុយ មានកន្ទេល ខ្នើយ ជាដើម ដល់សាធារណជន ដែលទីទ័លក្រលំបាក ឬ មួយក៏កសាងសាលារៀន សាលាសំណាក់ ស្ពាន ជីកអណ្ដូង ជីកស្រះជាដើម ទុកជាកុសលសាធារណៈ ដើម្បីឲ្យសាធារណជនបានទទួលប្រើប្រាស់ពល់គ្នា ។

ឃ- ប្រគេនគិលានភេសជ្ជប្បច្ច័យ គឺទុសថដល់ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ដែលមានជម្ងឺ ឬ ក៏ចែកឱសថដល់ជនសាធារណៈ ដែលមានជម្ងឺឈឺចាប់ ។

www.budinst.gov.kh www.elibraryofcambodia.org

ការធ្វើទានដោយបច្ច័យទាំង ៤ ខាងលើនេះ អ្នកកាន់ព្រះពុទ្ធសាសនាជាតិខ្មែរ រមែងតែងបានធ្វើជាញឹកញាប់រឿយ ៗ ដោយមានជំនឿជឿព្រះពុទ្ធភាសិតថា អ្នកមានចិត្តល្អ តែងបានសេចក្ដីសុខ អ្នកសង្គ្រោះគេ តែងទទួលសេចក្ដីសង្គ្រោះវិញ អ្នកបូជាគេ តែងបានការបូជាវិញ អ្នកដែលប្រាថ្នាចង់បានសេចក្ដីសុខដល់ខ្លួន ហើយធ្វើឲ្យកើតទុក្ខដល់អ្នកដទៃ នោះនឹងមិនសម្រេចដូចបំណងឡើយ នឹងត្រឡប់បានសេចក្ដីទុក្ខទៅវិញ លុះតែចែកសេចក្ដីសុខដល់អ្នកដទៃ ទើបសេចក្ដីសុខនោះនឹងត្រូវត្រឡប់បានមកវិញ ។

**២ រក្សាសីល** គឺតាំងចិត្តវៀរលែងប្រព្រឹត្តធ្វើអំពើអាក្រក់ ៥ យ៉ាង ហៅថា សីល ៥ (និច្ចសីល) គឺ

ក- មិនសម្លាប់សត្វ ទោះធំក្ដីតូចក្ដី

ខ- មិនលួចទ្រព្យសម្បត្តិអ្នកដទៃ ទោះតិចក្ដីច្រើនក្ដី

គ- មិនប្រព្រឹត្តបំពានបំពារក្នុងផ្លូវកាម លើកូនប្រពន្ធអ្នកដទៃ

www.budinst.gov.kh www.elibraryofcambodia.org

ឃ- មិននិយាយកុហក

ង- មិនផឹកទឹកស្រវឹងដែលធ្វើឲ្យខ្លួនវង្វេងវង្វាន់ក្តីគំនិត

ពុទ្ធសាសនិកជាតិខ្មែរ ដែលបានរក្សាសីល ៥ ខាងលើនេះខ្ជាប់ខ្ជួនហើយ ខ្លះក៏បានរក្សាសីល (ឧបោសថសីល) តទៅទៀត ខ្លះក៏បានរក្សារហូតដល់សីល ១០ (អតិរេកសីល) ក៏មាន ។

---

ពុទ្ធសាសនិកជាតិខ្មែរ ដែលនាំគ្នារក្សាសីល ៥ ជាដើមដូចខាងលើនេះ ជានិច្ចនិរន្តរ៍ដោយមានជំនឿជឿពាក្យប្រៀនប្រដៅព្រះពុទ្ធជាម្ចាស់ថា អ្នកដែលត្រូវការចង់បានសេចក្តីសុខ ត្រូវឲ្យមានមេត្តាធម៌ គឺសេចក្តីអាណិត ប្រកប់អានចំពោះខ្លួនឯងផង ចំពោះមនុស្សសត្វទៅផង មិនត្រូវបៀតបៀន ឬមើលងាយអ្នកដទៃណាមួយឡើយ ព្រោះមនុស្សសត្វទាំងអស់ក្នុងលោក ត្រូវការចង់រស់នៅដូចគ្នា ចង់ឲ្យមានទ្រព្យសម្បត្តិដូចគ្នា ចង់ឲ្យគ្រួសាររបស់ខ្លួនមានតម្លៃថ្លៃថ្នូរដូចគ្នា ចង់ឲ្យបានរួចផុតពីការកុហក

www.budinst.gov.kh www.elibraryofcambodia.org

ហោគបញ្ចោគពីសំណាក់អ្នកដទៃដូចគ្នា ចង់ឲ្យមានប្រាជ្ញាក៏ស្វាន់ដូចគ្នា ។

**៣-បំរើនភាវនា** គឺការរំលួនចិត្ត ការហាត់ចិត្ត កុំឲ្យចិត្តជាប់នៅក្នុងអារម្មណ៍អាក្រក់ដែលសម្រាប់ធ្វើចិត្តឲ្យសៅហ្មង ឲ្យបានចិត្តនៅក្នុងអារម្មណ៍ដ៏ល្អ ដែលសម្រាប់ធ្វើចិត្តឲ្យបានស្អាតល្អ

ពុទ្ធសាសនិកជាតិខ្មែរ ពេញចិត្តនឹងការបំរើនភាវនានេះណាស់ ដោយមានជំនឿជឿពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ថា អំពើអាក្រក់គ្រប់យ៉ាង កើតឡើងអំពីចិត្តអាក្រក់ អំពើល្អគ្រប់យ៉ាង កើតឡើងអំពីចិត្តល្អ ។ ចិត្តអាក្រក់ គឺចិត្តដែលសៅហ្មងដោយលោភៈ ទោសៈ មោហៈ ចិត្តល្អគឺចិត្តដែលមិនសៅហ្មង ដោយលោភៈ ទោសៈ មោហៈ ។ ចិត្តអាក្រក់តែងដឹកនាំមនុស្សឲ្យធ្វើអំពើអាក្រក់ មានកាប់សម្លាប់គេ លួចទ្រព្យសម្បត្តិគេ ឬ នាំឲ្យមានការឈ្លោះប្រកែកជាដើម ចិត្តល្អតែងនាំមនុស្សឲ្យធ្វើអំពើល្អ

www.budinst.gov.kh www.elibraryofcambodia.org

មានការជួយសង្គ្រោះអ្នកដទៃជាដើម ។ មនុស្សចិត្តអាក្រក់ បើទៅកន្លែងណា កន្លែងនោះមិនបានសេចក្ដីសុខស្រួលទេ រីឯមនុស្សចិត្តល្អ បើនៅត្រង់ទីណា ទីនោះសុខសប្បាយ ឥតមានរឿងឈ្លោះប្រកែកអ្វីឡើយ ។

ប្រជាកស្ត្រខ្មែរ ដែលមានជំនឿចំពោះព្រះពុទ្ធសាសនា មិនមែនគ្រាន់តែធ្វើតានក្សាសីល និងការនាដូចខាងលើនេះ ហើយក៏ឈប់ស្ងៀមព្រងើយកន្តើយឡើយ បានតាំងខំប្រឹងបំពេញកិច្ចការផ្សេង ៗ ដែលមានប្រយោជន៍ដល់ប្រទេសជាតិ ជាពិសេសដល់ជីវភាពរៀង ៗ ខ្លួនផងទៀត ព្រោះប្រជាកស្ត្រខ្មែរ បានទទួលការសិក្សានិងការអប់រំតាមគន្លងព្រះពុទ្ធសាសនា ជាយូរអង្វែងណាស់ហើយតាំងពីបុព្វបុរសរបស់ខ្លួនជាប់តមក ដោយមានគម្ពីរសៀវភៅតម្រាប់តម្រាសម្រាប់ប្រដៅប្រជាពលរដ្ឋ ច្រើនតែជាប់ទាក់ទងនឹងព្រះពុទ្ធសាសនាទាំងអស់ ដូចមានស្រង់យកមកបរិកេទុកជាក័ស្ដុតាងខ្លះដូចតទៅនេះ ៖

www.budinst.gov.kh www.elibraryofcambodia.org

១- **សង្គមមនុស្ស** ដែលមានគ្នាតាំងពីពីរនាក់ឡើងទៅ បើមានការព្រមព្រៀងគ្នា ទើបបានសេចក្ដីសុខ ។

២- **កុំបង្កឲ្យមានរឿងវិវាទ** គឺការឈ្លោះប្រកែករវាងគ្នានិងគ្នាឡើយ ព្រោះការឈ្លោះប្រកែកគ្នា ជាហេតុនាំឲ្យដល់សេចក្ដីវិនាស ។

៣- **ត្រូវឲ្យមានខន្តីធម៌** គឺការអត់ធន ឬការទប់ចិត្ត កុំខឹងប្រទេញ្ញាតផ្ដេសផ្ដាស ព្រោះកំហឹងនាំឲ្យយល់ខុស ។

៤- **មិនត្រូវបៀតបៀនអ្នកណាមួយ** ឲ្យគេបានទុក្ខទោសទេ ព្រោះក្នុងលោកនេះចង់បានតែសុខ-ចំរើន ដូចគ្នា ។

៥- **ត្រូវខំប្រឹងសិក្សា** ឬ ខំប្រឹងធ្វើការងារដោយយកចិត្តទុកដាក់ ។ ការខំប្រឹងនោះអាចនាំឲ្យសម្រេចប្រយោជន៍ដែលខ្លួនត្រូវការ ។

៦- **មិនត្រូវខ្ជិលច្រអូសឡើយ** ព្រោះកំ-

www.budinst.gov.kh www.elibraryofcambodia.org

ជិលនោះ អាចនាំខ្លួនឲ្យទៅជួបនឹងការហិនហោច ។

៧— **ត្រូវឲ្យមានកតញ្ញូតានិងកតវេទិ-តា** គឺដឹងគុណនិងតបគុណចំពោះអ្នកដែលមានគុណូប-ការៈលើខ្លួន ព្រោះការដឹងគុណ ជាធម៌របស់មនុស្ស ។

៨— **មិនត្រូវប្រមាថមើលងាយ** អ្នកឯ-ទៀតដែលទន់ទាបជាងខ្លួន ដែលក្រីក្រជាងខ្លួន និងល្ងង់ជាងខ្លួនឡើយ ព្រោះការមើលងាយគេ នឹងឲ្យផលអា-ក្រក់ដល់ខ្លួន ។

៩— **កើតបានជាមនុស្សហើយ** គួរតែក្សាឋានៈរបស់មនុស្សឲ្យគង់នៅ កុំឲ្យឋានៈនោះធ្លាក់ ទៅនៅស្មើគ្នានិងឋានៈរបស់តិរច្ឆាន

១០— **ជីវិតមនុស្សជាអសារៈ** ឥតមានខ្លឹមសារទេ ប៉ុន្តែអ្នកមានគំនិតល្អអាចធ្វើឲ្យជីវិតមានសារៈ គឺខ្លឹមសារបាន ។

ចប់ដោយសង្ខេប

www.budinst.gov.kh www.elibraryofcambodia.org

មានជាវទុំ និង ពយ

នុវបណ្ណាគារ ក្រៃ គ្រេន៍ លេខ136

វិថីខេមរភូមិន្ទ ពជធានីភ្នំពេញ

ក្រុមនិមន្តនិងអភ្ជាញ្ញា ដោយ

មេត្រីភាព

www.budinst.gov.kh www.elibraryofcambodia.org